# ពិធីអាពាហ៍ពិពាហ៍របស់ព្រះសហគមន៍កាតូលិក
# តាមរបៀបព្រះសហគមន៍ទូទៅ

*លោកបូជាចារ្យចេញទៅស្វាគមន៍កូនកំលោះ- កូនក្រមុំនៅមាត់ទ្វារព្រះវិហារ*

## ១-ពិធីប្រារព្ធ

*លោកបូជាចារ្យដង្ហែ ដើរនាំ កូនកំលោះ និងកូនក្រមុំចូលព្រះវិហារ*

**បន្ទរៈ យើងសែនសប្បាយ យាត្រាឆ្ពោយទៅព្រះតំណាក់**
**ទាំងយើងច្រៀងបទថ្មី សរសើរព្រះម្ចាស់ អាលេលូយ៉ា ។**

១- មហាជនគ្រប់ប្រទេស ចូរអ្នកអបអរសាទរ
ហើយថ្វាយស័ព្ទវាចា ថ្វាយព្រះអម្ចាស់របស់យើង ។

២- យើងជាស្នាព្រះហស្ត របស់ព្រះថ្លៃពន្លក
ជាប្រជាជនសុខ ដែលព្រះអង្គថៃណែនាំ ។

៣- ព្រះជាម្ចាស់ទ្រង់មាន ព្រះហឫទ័យមេត្តា
សប្បុរសករុណា ដែលស្ថិតនៅជាប់អស់កល្ប ។

*ជំនួយលោកបូជាចារ្យអុជធូបចម្លងពន្លឺពីទៀនព្រះជ័យ ដាក់នៅខាងមុខ កូនកំលោះ-កូនក្រមុំ ពេលមកដល់កន្លែងមុខអាសនៈ លោកបូជាចារ្យស្វាគមន៍*

ប . ក្នុងព្រះនាម ព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ

គ្រ. ***អាម៉ែន។***

ប . សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន។

គ្រ. ***ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង***

បងប្អូនជាទីស្រឡាញ់ ! នៅថ្ងៃនេះ យើងមានសេចក្ដីសប្បាយរីករាយដោយបានជួបជុំគ្នា ធ្វើជាសាក្សីបន្ទាល់នៃពាក្យសន្យារបស់ប្អូនទាំងពីរ ។ ប្អូនទាំងពីរ មកទីនេះដើម្បីទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ និងសូមព្រះជាម្ចាស់ប្រទានពរនៅចំពោះមុខគ្រីស្ដបរិស័ទទាំងអស់ ដែលជាគ្រួសារតែមួយក្នុងព្រះសហគមន៍ ។

ជាការពិតណាស់ ព្រះយេស៊ូគ្រីស្ដ ទ្រង់ពោរពេញដោយព្រះទ័យមេត្តាករុណា និងពោរពេញដោយសេចក្ដីស្រឡាញ់ ទ្រង់នឹងប្រទានពរឲ្យប្អូនទាំងពីរនូវសុភមង្គល ទឹកចិត្តស្វាមីភក្ដីស្មោះត្រង់ រវាងគ្នានឹងគ្នា នឹងប្រទាននូវកម្លាំងដ៏ខ្លាំងក្លា ដើម្បីបំពេញភារកិច្ចក្នុងព្រះសហគមន៍ ។

*ប្រសិនបើពិធីអាពាហ៍ពិពាហ៍ អត់មានអភិបូជា សូមរំលង ពិធីលើកលែងទោស ទៅ "អធិដ្ឋានពេលចូល" តែម្តង។*

## ពិធីលើកលែងទោស

**ប.** យើងទទួលសារភាពថា យើងជាអ្នកមានបាប សូមព្រះជាម្ចាស់ ជួយជំរះចិត្តគំនិតគូស្រករថ្ងៃនេះនិងយើងទាំងអស់គ្នា ដើម្បីចូលរួមអភិបូជាដោយសមរម្យ

*ខ្ញុំសូមទទួលសារភាព ចំពោះព្រះដ៏មានឫទ្ធានុភាពសព្វប្រការ*
*ហើយចំពោះអស់បងប្អូនផងថា ខ្ញុំបានប្រព្រឹត្តអំពើបាបច្រើន*
*ដោយកាយវាចាចិត្ត និងដោយខានបំពេញកិច្ចការរបស់ខ្ញុំ (គក់ទ្រូង)*
*ទោសខ្ញុំអើយ ទោសខ្ញុំអើយ ទោសខ្ញុំអើយធ្ងន់ណាស់។*
*ហេតុនេះ សូមព្រះនាងព្រហ្មចារិនីម៉ារី អស់ទេវទូត និងសន្តបុគ្គលទាំងឡាយ*
*ព្រមទាំងអស់បងប្អូន សូមជួយអង្វរព្រះជាអម្ចាស់ឲ្យខ្ញុំផង។*

*លោកបូជាចារ្យ សូមព្រះជាម្ចាស់លើកលែងទោសឲ្យអង្គប្រជុំ ៖*

សូមព្រះដ៏មានឫទ្ធានុភាពសព្វប្រការ ទ្រង់ព្រះមេត្តាលើកលែងទោសឲ្យយើងខ្ញុំរួចពីបាប ព្រមទាំងប្រទានជីវិតអស់កល្បជានិច្ច ឲ្យយើងខ្ញុំ។

គ្រ. ***អាម៉ែន។***

*បន្ទាប់មក លោកបូជាចារ្យ សូត្រដូចខាងក្រោមនេះ ៖*

ឱ ព្រះអម្ចាស់អើយ! សូមអាណិតអាសូរ ***(អង្គប្រជុំថាតាម)***

ឱ ព្រះគ្រីស្តអើយ! សូមអាណិតអាសូរ ***(អង្គប្រជុំថាតាម)***

ឱ ព្រះអម្ចាស់អើយ! សូមអាណិតអាសូរ ***(អង្គប្រជុំថាតាម)***

## អធិដ្ឋានពេលចូល

ឱ! ព្រះបិតាដ៏មានតេជានុភាពសព្វប្រការអើយ យើងខ្ញុំសូមទ្រង់ព្រះមេត្តាប្រោសស្តាប់នូវពាក្យអង្វររបស់យើងខ្ញុំ ជាប្រយោជន៍ដល់គូស្រករទាំងពីរនេះគឺ ...................... និង........................ ដែលបានមកទីនេះដើម្បីនឹងទទួល អគ្គសញ្ញាអាពាហ៍ពិពាហ៍ ភ្ជាប់គ្នាជាស្វាមី-ភរិយា តាមច្បាប់គ្រីស្តសាសនា សូមទ្រង់ប្រោសប្រទានព្រះពរលើគូស្រករទាំងពីរនេះ ហើយពង្រីកសេចក្តីស្រឡាញ់ឲ្យគេព្រមព្រៀងរួមសុខរួមទុក្ខជាមួយគ្នាអស់មួយជីវិត ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាព្រះអង្គ និងជាព្រះអម្ចាស់ ដែលសោយរាជ្យរួមជាមួយព្រះអង្គ និងព្រះវិញ្ញាណដ៏វិសុទ្ធអស់កល្បជាអង្វែងតរៀងទៅ។

គ្រ. ***អាម៉ែន។***

## ២-ពិធីលើកតម្កើងព្រះបន្ទូលព្រះជាម្ចាស់

### សូមថ្លែងលិខិតទីមួយ របស់លោកប៉ូលផ្ញើជូនគ្រីស្តបរិស័ទនៅក្រុងកូរិនថូស(១កថ ១៣,១-៧)

ទោះបីជាខ្ញុំចេះនិយាយភាសារបស់មនុស្សលោក និងភាសារបស់ទេវទូតក្តី បើសិនជាខ្ញុំគ្មានសេចក្តីស្រឡាញ់ទេ ខ្ញុំប្រៀបដូចជាសម្លេងគងដែលលាន់ឮឡើង ឬដូចជាស្គរដែលឮរំពងឡើងតែប៉ុណ្ណោះ។ ទោះបីខ្ញុំទទួលព្រះអំណោយទានខាងថ្លែងព្រះបន្ទូលនិងស្គាល់គម្រោងការដ៏លាក់កំបាំងទាំងអស់ ព្រមទាំងមានចំណេះគ្រប់យ៉ាង ហើយទោះបីខ្ញុំមានជំនឿមាំ រហូតដល់ធ្វើឲ្យភ្នំ រើពីកន្លែងមួយទៅកន្លែងមួយទៀតបានក្តី តែបើសិនជាខ្ញុំគ្មានសេចក្តីស្រឡាញ់ទេនោះ ខ្ញុំជាមនុស្សឥតបានការអ្វីទាំងអស់។ ទោះបីខ្ញុំយកទ្រព្យសម្បត្តិរបស់ខ្ញុំ ទាំងប៉ុន្មានទៅចែកទានក្តី ទោះបីខ្ញុំសុខចិត្តឲ្យគេយករូបកាយខ្ញុំ ទៅដុតទាំងរស់ក្តី តែបើសិនខ្ញុំគ្មានសេចក្តីស្រឡាញ់ទេនោះ ក៏គ្មានប្រយោជន៍អ្វីដល់ខ្ញុំដែរ។ អ្នកមានចិត្តស្រឡាញ់ តែងតែអត់ធ្មត់ ជួយធុរៈគេ ហើយមិនចេះឈ្នានីសគេទេ។ អ្នកមានចិត្តស្រឡាញ់ មិនវាយឫកខ្ពស់ មិនអួតបំប៉ោង ទ្បើយ។ អ្នកមានចិត្តស្រឡាញ់ មិនប្រព្រឹត្តអំពើថោកទាប មិនស្វែងរកប្រយោជន៍ផ្ទាល់ខ្លួន មិនមួម៉ៅ មិនចង់គំនុំ មិនអបអរនឹងអំពើទុច្ចរិតទេ តែរីករាយនឹងសេចក្តីពិតវិញ។ អ្នកមានចិត្តស្រឡាញ់ អត់ឱនឲ្យទាំងអស់ ជឿទាំងអស់ សង្ឃឹមទាំងអស់ ហើយទ្រាំទ្រទាំងអស់។ ឥឡូវនេះមានសេចក្តី បីយ៉ាងគឺ ជំនឿ សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់។ ប៉ុន្តែសេចក្តីស្រឡាញ់វិសេសជាងគេបំផុត។

### ឬ សូមថ្លែងព្រះគម្ពីរ បេនស៊ីរ៉ាក (បសរ ២៦, ១-៤)

ស្វាមីមានភរិយាចិត្តល្អ ពិតជាមានសុភមង្គល និងមានអាយុវែង មួយទ្វេជាពីរ ភរិយាក្លាហាន តែងតែធ្វើឲ្យស្វាមីមានអំណរសប្បាយ និងស្គាល់តែសេចក្តីសុខអស់មួយជីវិត។ ស្វាមីដែលមានភរិយាចិត្តល្អពិតជាមានសំណាង ព្រោះជាអំណោយទាន ដែលព្រះអម្ចាស់ប្រទានឲ្យអ្នកគោរពកោតខ្លាចព្រះអង្គ។ ទោះបីជាគេ ក្រក្តី មានក្តី ក៏គេនៅតែមានចិត្តសប្បាយ មានទឹកមុខរីករាយគ្រប់ពេលវេលា។

## ឬ សូមថ្លែងលិខិតរបស់គ្រីស្ដទូតប៉ូល ផ្ញើជូនគ្រីស្ដបរិស័ទ ក្រុងអេភេសូ

*(អភ ៥:២,២៥-៣២)*

ចូររស់នៅដោយមានចិត្តស្រឡាញ់ដូចព្រះគ្រីស្ដបានស្រឡាញ់យើង ហើយបានបូជាព្រះជន្មសម្រាប់យើងទុកជាតង្វាយ ថ្វាយព្រះជាម្ចាស់ និងទុកជាយញ្ញបូជាដែលគាប់ព្រះហឫទ័យព្រះអង្គ។ ចំពោះបងប្អូនដែលមានប្រពន្ធវិញ ចូរស្រឡាញ់ភរិយា ដូចព្រះគ្រីស្ដបានស្រឡាញ់ព្រះសហគមន៍ដែរ ព្រះអង្គបូជាព្រះជន្មរបស់ព្រះអង្គផ្ទាល់សម្រាប់ព្រះសហគមន៍ ដើម្បីប្រោសឲ្យព្រះសហគមន៍បានទៅជាវិសុទ្ធ ទាំងជម្រះឲ្យបានស្អាតបរិសុទ្ធ ដោយលាងក្នុងទឹក និងដោយសារព្រះបន្ទូល។ ព្រះអង្គសព្វព្រះហឫទ័យនាំព្រះសហគមន៍នេះ មកថ្វាយព្រះអង្គផ្ទាល់ ជាព្រះសហគមន៍ដ៏រុងរឿង ឥតស្លាកស្នាម ឥតជ្រីវជ្រួញ និងឥតខ្ចោះត្រង់ណាឡើយ គឺឲ្យបានទៅជាវិសុទ្ធ ឥតសៅហ្មង។ ដូច្នេះស្វាមីត្រូវស្រឡាញ់ភរិយាឲ្យបានដូចស្រឡាញ់រូបកាយរបស់ខ្លួនដែរ។ អ្នកណាស្រឡាញ់ភរិយា អ្នកនោះស្រឡាញ់ខ្លួនឯង។ ពុំដែលមាននរណាម្នាក់ ស្អប់រូបកាយរបស់ខ្លួនឡើយ ផ្ទុយទៅវិញ គេតែងចិញ្ចឹមបីបាច់ថែរក្សារូបកាយនោះដូចព្រះគ្រីស្ដចិញ្ចឹម បីបាច់ថែរក្សាព្រះសហគមន៍ ព្រោះយើងទាំងអស់គ្នាជាសរីរាង្គនៃព្រះកាយរបស់ព្រះអង្គ។ ហេតុនេះហើយបានជាបុរសត្រូវចាកចេញពីឪពុកម្ដាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរនឹងបានទៅជារូបកាយតែមួយ គម្រោងការ ដ៏លាក់កំបាំងនេះ មានអត្ថន័យជ្រៅណាស់ ខ្ញុំនិយាយសេចក្ដីនេះសំដៅលើព្រះគ្រីស្ដ និងព្រះសហគមន៍តែប៉ុណ្ណោះ។

**ប . នេះជាព្រះបន្ទូលរបស់ព្រះអម្ចាស់។**

**គ្រ.** *សូមអរព្រះគុណព្រះជាម្ចាស់។*

## **ស្មូតទំនុកតម្កើងលេខ ៤៥** *( បទព្រហ្មគិត )*

១- ឱ! កូនស្រីស្រស់ឆើត  នេត្រាអើតត្រចៀកស្តាប់
បំភ្លេចញាត្តិផៅគ្រប់  ប្រជារាស្ត្រនិងម៉ែឪ ។
២- ស្តេចទ្រង់សព្វព្រះទ័យ  គន់រំពៃពេញជាត្រូវ
សម្រស់មិនសខ្មៅ  ព្រះទ័យញ័រព្រះកាយញាក់ ។
៣- ព្រះអង្គជាម្ចាស់នាង  កុំដើរឃ្វាងបែបស្ទើរស្ទាក់
សិរសាកំពូលអ្នក  ក្រាបថ្វាយបង្គំព្រះអង្គ ។
៤- គេនាំនាងចូលជិត  មានបក់ផ្លិតចំរៀងផង
ត្រេកអរស្រែកអ៊ឹងកង  ចូលព្រះរាជ្យវាំងស្តេច ។

ឬ

## **ស្មូតទំនុកតម្កើងលេខ ៣៤** *( បទពាក្យ ៨ )*

២- ចិត្តខ្ញុំតម្កើងព្រះជាម្ចាស់  សូមឲ្យឮច្បាស់ដល់អ្នកសុភាព
និងបានសប្បាយរីករាយដរាប  បានជ្រួតជ្រាបពីព្រះឫទ្ធា ។
៣- សូមអរសាទរថ្វាយព្រះអម្ចាស់  ប្រសើរក្រៃណាស់នៅលើលោកា
ចូរអរសាទរនឹងយើងរាល់គ្នា  តម្កើងនាមារបស់ព្រះអង្គ ។
៤- ខ្ញុំខំស្វែងរកព្រះម្ចាស់លោកា  ហើយទ្រង់មេត្តាបំពេញបំណង
ទ្រង់រំដោះខ្ញុំពីក្តីសៅហ្មង  និងអន្តរាយសព្វគ្រប់ប្រការ ។
៥- អស់អ្នកជឿជាក់លើព្រះអង្គ  សង្ឃឹមលើទ្រង់រាល់ពេលវេលា
និងត្រេកអរសប្បាយក្នុងដួងចិន្តា គ្មានអ្វីដែលថាគួរខ្មាសអៀនឡើយ។

### **អាលេលូយ៉ា**

ច្រៀងអាលេលូយ៉ា  ថ្វាយព្រះម្ចាស់  ច្រៀងអាលេលូយ៉ា  ថ្វាយព្រះម្ចាស់
ច្រៀងអាលេលូយ៉ា  ថ្វាយព្រះម្ចាស់  ច្រៀងអាលេលូយ៉ា  ថ្វាយព្រះម្ចាស់

**សូមថ្លែងព្រះគម្ពីរដំណឹងល្អតែងដោយសន្ដម៉ាថាយ** *(មថ ២២,៣៥-៤០)*

ក្នុងចំណោមពួកគេ មានម្នាក់ជាបណ្ឌិតខាងវិន័យទូលសួរព្រះយេស៊ូ ក្នុងគោលបំណងល្បងលមើលព្រះអង្គថា៖ «លោកគ្រូ! ក្នុងគម្ពីរវិន័យ តើមានវិន័យណាសំខាន់ជាងគេ?»។ ព្រះយេស៊ូមានព្រះបន្ទូលថា៖ «″ត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នកឲ្យអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីប្រាជ្ញា″ ហ្នឹងហើយជាវិន័យទីមួយដែលសំខាន់ជាងគេបំផុត។ រីឯវិន័យទីពីរក៏សំខាន់ដូចគ្នាដែរ គឺ ត្រូវស្រឡាញ់បងប្អូន ឯទៀតៗ ឲ្យដូចស្រឡាញ់ខ្លួនឯង″។ វិន័យទាំងពីរនេះ ជាឫសគល់របស់គម្ពីរវិន័យ និងគម្ពីរព្យាការីទាំងអស់»។

ឬ

**សូមថ្លែងព្រះគម្ពីរដំណឹងល្អតែងដោយសន្ដម៉ាកុស** *(មក ១០,៦-១២)*

កាលដើមដំបូង នៅពេលដែលព្រះជាម្ចាស់បានបង្កើតពិភពលោក «ព្រះអង្គបង្កើតមនុស្សមកជាបុរស ជាស្ត្រី» ។ ហេតុនេះហើយ បានជាបុរសត្រូវចាកចេញ ពីឪពុកម្ដាយ ទៅរួមរស់ជាមួយភរិយារបស់ខ្លួន ហើយអ្នកទាំងពីរត្រឡប់ទៅជារូបកាយតែមួយ គេមិនមែនជាបុគ្គលពីនាក់ទៀតទេ គឺរូបកាយតែមួយវិញ។ ដូច្នេះ មនុស្សមិនត្រូវបំបាក់បំបែកគូរស្រករដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ។ ពេលទៅដល់ផ្ទះ ពួកសាវ័កទូលសួរព្រះយេស៊ូអំពីរឿងនេះម្ដងទៀត។ ព្រះអង្គមានព្រះបន្ទូលទៅគេថា៖ «ប្រសិនបើស្វាមីណាលែងភរិយា ហើយទៅរៀបការនឹងស្ត្រី ម្នាក់ទៀត ស្វាមីនោះបានផិតក្បត់ភរិយារបស់ខ្លួន។ រីឯភរិយាណាដែលលែងស្វាមី ហើយទៅរៀបការនឹងបុរសម្នាក់ទៀត ស្ត្រីនោះក៏បានប្រព្រឹត្តអំពើផិតក្បត់ដែរ»។

ឬ

## សូមថ្លែងព្រះគម្ពីរដំណឹងល្អតែងដោយសន្តយ៉ូហាន *(យហ ១៥, ៩-១២)*

ខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដូចព្រះបិតាស្រឡាញ់ខ្ញុំដែរ។ ចូរទុកសេចក្តីស្រឡាញ់របស់ខ្ញុំឲ្យស្ថិតនៅជាប់នឹងអ្នករាល់គ្នាចុះ។ បើអ្នករាល់គ្នាប្រតិបត្តិតាមវិន័យរបស់ខ្ញុំ អ្នករាល់គ្នាពិតជាទុកសេចក្តីស្រឡាញ់របស់ខ្ញុំ ឲ្យស្ថិតនៅជាប់នឹងអ្នករាល់គ្នាមែនដូចខ្ញុំប្រតិបត្តិតាមវិន័យរបស់ព្រះបិតាហើយទុកឲ្យ សេចក្តីស្រឡាញ់របស់ព្រះអង្គស្ថិតនៅជាប់នឹងខ្ញុំដែរ។ ខ្ញុំបាននិយាយសេចក្តីទាំងនេះប្រាប់អ្នករាល់គ្នា ដើម្បីឲ្យអំណររបស់ខ្ញុំស្ថិតនៅក្នុងអ្នករាល់គ្នាហើយដើម្បីឲ្យអ្នករាល់គ្នាមានអំណរពេញលក្ខណៈ។ វិន័យរបស់ខ្ញុំមានដូចតទៅនេះគឺ អ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់ អ្នករាល់គ្នាដែរ។

ប. នេះជាព្រះបន្ទូលដំណឹងល្អរបស់ព្រះអម្ចាស់។

គ្រ. *សូមកោតសរសើរព្រះអម្ចាស់យេស៊ូគ្រីស្ត។*

- **ធម្មទេសនា**

## ៣-ពិធីសន្ធានាខាងលោកបូជាចារ្យ និងកូនកំលោះ-កូនក្រមុំ

*លោកបូជាចារ្យ ប្រកាសអញ្ជើញ ឪពុកម្តាយ សាក្សីបន្ទាល់ និងក្រុមសាច់សារលោហិតទទួលពាក្យសន្យារបស់ កូនកំលោះ-កូនក្រមុំ ។ គូស្រករទាំងពីរលើកដៃប្រណម្យ។*

**បន្ទរ៖** **ព្រះជាម្ចាស់ទ្រង់បានជ្រើសរើសយើង ទ្រង់លើកតម្កើងតំកល់ទុក**
**តទៅមុខតាមរយៈព្រះគ្រីស្ត ឲ្យទៅជាប្រជាជនថ្លៃថ្លា ។**

១- សូមនាំគ្នាលើកតម្កើងព្រះ ជាអម្ចាស់វរៈព្រះបិតា
នៃព្រះយេស៊ូគ្រីស្តសាស្តា ព្រះម្ចាស់នៃយើងទ្រង់ជាស្ថាន
ព្រះអង្គប្រោសពរគ្រប់បែបយ៉ាង ពរថ្មីស្រឡាងទ្រង់ប្រទាន
ចេញមកឲ្យយើងពីវិញ្ញាណ ព្រះយេស៊ូគ្រីស្តបរមសុខ ។

*លោកបូជាចារ្យ សួរយោបល់ កូនកំលោះ - កូនក្រមុំ ។ ជំនួយពិធីបុណ្យរៀបចំមីក្រូ។*

ប. នៅចំពោះមុខព្រះសហគមន៍ទាំងមូល ខ្ញុំសូមសួរបញ្ជាក់ប្អូនទាំងពីរដូចតទៅ៖

១- តើប្អូនទាំងពីរសុខចិត្ត ទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ ដោយដួងចិត្តស្មោះស្ម័គ្រ ពិតប្រាកដគ្មានការបង្ខិតបង្ខំពីនរណាឬទេ ?

*កូនកំលោះ* ៖ **បាទ ខ្ញុំស្មោះស្ម័គ្រដោយខ្លួនឯង គ្មានការបង្ខិតបង្ខំទេ ។**

*កូនក្រមុំ* ៖ **ចាស ខ្ញុំស្មោះស្ម័គ្រដោយខ្លួនឯង គ្មានការបង្ខិតបង្ខំទេ ។**

២- ក្នុងការរួមរស់ជាគូស្វាមី-ភរិយា តើប្អូនទាំងពីរសុខចិត្តស្រឡាញ់គ្នា និងគោរពគ្នាទៅវិញទៅមក អស់មួយជីវិតឬទេ ?

*ឆ្លើយរួមគ្នា* ៖ **ចាស / បាទ ខ្ញុំសុខចិត្ត ។**

៣- តើប្អូនទាំងពីរយល់ព្រមទទួលកូនៗដែលព្រះជាម្ចាស់ នឹងប្រទានឲ្យ ព្រមទាំងសុខចិត្តទូន្មានប្រដៅកូនៗទាំងនោះ ឲ្យរស់នៅតាមក្រិត្យវិន័យរបស់ព្រះយេស៊ូ និងរបស់ព្រះសហគមន៍ឬទេ ?

*ឆ្លើយរួមគ្នា* ៖ **ចាស / បាទ ខ្ញុំសុខចិត្ត ។**

## ៤-ការប្តូរពាក្យស្ម័គ្រចិត្តរវាង កូនកំលោះ និង កូនក្រមុំ

*កូនកំលោះ-កូនក្រមុំបែរមុខរកគ្នា ទាំងលើកដៃប្រណម្យ ។*

*កូនកំលោះ* បង............................ស្ម័គ្រចិត្តទទួលអូន.......................ធ្វើជាភរិយា ហើយសន្យាថា នឹងស្មោះត្រង់ជាមួយអូន ទាំងក្នុងពេលមានសេចក្តីសុខ ក៏ដូចជាពេលមានទុក្ខព្រួយ ទាំងក្នុងពេលមានអាសន្ន ជម្ងឺឈឺចាប់ ក៏ដូចជាពេលមានសុខភាពល្អ ។ បងប្តេជ្ញាស្រឡាញ់អូន និងគោរពអូន អស់មួយជីវិត។

***កូនក្រមុំ*** អូន............................ស្ម័គ្រចិត្តទទួលបង......................ធ្វើជាស្វាមី ហើយសន្យាថា នឹងស្មោះត្រង់ជាមួយបង ទាំងក្នុងពេលមានសេចក្ដីសុខ ក៏ដូចជាពេលមានទុក្ខព្រួយ ទាំងក្នុងពេលមានអាសន្ន ជម្ងឺឈឺចាប់ ក៏ដូចជាពេលមានសុខភាពល្អ ។ អូនប្ដេជ្ញាស្រឡាញ់បង និងគោរពបង អស់មួយជីវិត ។

ប. ប្អូនទាំងពីរបានផ្ដល់ការស្ម័គ្រចិត្ត នៅចំពោះព្រះភ័ក្ត្រព្រះជាម្ចាស់ និង ព្រះសហគមន៍ហើយ សូមព្រះជាម្ចាស់ប្រោសប្រណី និងទ្រទ្រង់ឲ្យរឹងមាំ និងប្រទានព្រះពរ + ពេញបរិបូរណ៍ដល់ប្អូនទាំងពីរ។ ហេតុដូច្នេះហើយ មនុស្សមិនត្រូវបំបាក់បំបែកគូស្រករ ដែលព្រះជាម្ចាស់បានផ្សំផ្គុំនោះឡើយ។*(មក ១០,៩)។*

គ្រ. ***អាម៉ែន។***

*លោកបូជាចារ្យ ប្រោះទឹកព្រះពរ លើកូនកំលោះ-កូនក្រមុំទាំងពីរ ។*

# ពិធីបំពាក់ចិញ្ចៀន

*លោកបូជាចារ្យ ធ្វើព្រះពរលើចិញ្ចៀនរបស់កូនកំលោះ-កូនក្រមុំ។ ហើយជំនួយលោកបូជាចារ្យម្នាក់កាន់ជើងពានដាក់ចិញ្ចៀន និងផ្ដិលទឹក រីឯកូនកំលោះ-កូនក្រមុំ បែរមុខរកគ្នា ដើម្បីបំពាក់ចិញ្ចៀន។*

ប. សូមព្រះជាម្ចាស់ប្រសិទ្ធិពរលើចិញ្ចៀនទាំងគូនេះ ដែលប្អូនទាំងពីរនឹងបំពាក់ឲ្យគ្នាទៅវិញទៅមក ទុកជាសក្ខីភាពនៃសេចក្ដីស្រឡាញ់ដ៏ស្មោះត្រង់ និងទុកចិត្តគ្នាទៅ

វិញទៅមកអស់មួយជីវិត ក្នុងព្រះនាមព្រះបិតា និងព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ ។

គ្រ. *អាម៉ែន ។*

*កូនកំលោះបំពាក់ចិញ្ចៀន ក្នុងម្រាមដៃនាង ដៃឆ្វេង របស់កូនក្រមុំ ដោយពោលថា៖*

កូនកំលោះ ៖ បងសូមបំពាក់ចិញ្ចៀននេះ ជូនអូនទុកជានិមិត្តរូបនៃភក្តីភាព និងសេចក្ដីស្រឡាញ់ដ៏ស្មោះស្ម័គ្រ អស់មួយជីវិតរបស់បង ។

ឬ

កូនកំលោះកាតូលិក៖ ..(ឈ្មោះកូនក្រមុំ)... សូមទទួលជញ្ចៀននេះ ទុកជាសញ្ញាបង្ហាញសេចក្ដីស្រឡាញ់ និងភក្ដីភាពរបស់បង ក្នុងនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

*កូនក្រមុំបំពាក់ចិញ្ចៀន ក្នុងម្រាមដៃនាង ដៃឆ្វេងរបស់កូនកំលោះ ដោយពោលថា៖*

*កូនក្រមុំ ៖* អូនសូមបំពាក់ចិញ្ចៀននេះ ជូនបងទុកជានិមិត្តរូបនៃភក្តីភាព និងសេចក្ដីស្រឡាញ់ដ៏ស្មោះស្ម័គ្រ អស់មួយជីវិតរបស់អូន ។

ឬ

កូនក្រមុំកាតូលិក ៖ ..(ឈ្មោះកូនកំលោះ)... សូមទទួលជញ្ចៀននេះ ទុកជាសញ្ញាបង្ហាញសេចក្ដីស្រឡាញ់ និងភក្ដីភាពរបស់អូន ក្នុងនាមព្រះបិតា ព្រះបុត្រា និងព្រះវិញ្ញាណដ៏វិសុទ្ធ។

*គូស្វាមី-ភរិយា ចាប់ដៃគ្នាទទួលព្រះពរ ហើយបែរមុខទៅលោកបូជាចារ្យ។*

ប. បពិត្រព្រះបិតាជាម្ចាស់ ! ព្រះអង្គសព្វព្រះហឫទ័យបង្កើតមនុស្សមានបុរសមានស្ត្រី ដើម្បីធ្វើជាសញ្ញាសំគាល់បង្ហាញ អំពីធម៌មេត្តាករុណារបស់ព្រះអង្គដែលស្រឡាញ់មនុស្សលោក ។ យើងខ្ញុំសូមលើកតម្កើងធម៌មេត្តាករុណារបស់ព្រះអង្គ និងសូមអរព្រះគុណព្រះអង្គផង ។ សូមទ្រង់ព្រះមេត្តាប្រោសប្រទានឲ្យ គូស្វាមីភរិយាថ្មីនេះ មានចិត្តស្រឡាញ់គ្នាយ៉ាងស្មោះ និងធ្វើជាសញ្ញាសំគាល់អំពីព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គចំពោះយើងខ្ញុំផង ។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រា ព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។

គ្រ. *អាម៉ែន។*

ប. បងប្អូនជាទីស្រឡាញ់ នៅពេលនេះ ក្នុងនាមព្រះសហគមន៍ ខ្ញុំសូមប្រកាសថា ប្អូនទាំងពីរនាក់ពិតជាភ្ជាប់គ្នា ជាគូស្វាមី-ភរិយាហើយ សូមបងប្អូនអបអរសាទរដោយទះដៃ។

*អ្នកចូលរួមទះដៃ គូស្រែករសំពះអរគុណ។*

## ធម៌អធិដ្ឋានសកល

ប. សូមបងប្អូនរួមចិត្តគំនិតជាមួយគ្នាអង្វរព្រះជាម្ចាស់ សូមព្រះអង្គប្រោសប្រទានឲ្យ គូស្វាមី-ភរិយា មានចិត្តស្រឡាញ់ដោយស្មោះអស់មួយជីវិត ទោះបីនៅគ្រាសប្បាយរីករាយក្តី នៅគ្រាពិបាកក្តី ។

១- សូមព្រះជាម្ចាស់ជាព្រះបិតា សំដែងធម៌មេត្តាករុណារបស់ព្រះអង្គ ដោយប្រទានឲ្យគូស្វាមី-ភរិយាថ្មី គឺ....................និង............. មានចិត្តខន្តី អត់អោន សន្តោសប្រណីឲ្យគ្នាជានិច្ច និងចេះអប់រំ ណែនាំគ្នាក្នុងជីវិតថ្មីដែលគេទាំងពីរ បានក្លាយទៅរូបកាយតែមួយ ហើយសុខចិត្តរួមរស់រួមស្លាប់ជាមួយព្រះគ្រីស្ត ក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ផង ។

**បន្ទរៈ ពេលណាយើងស្រឡាញ់គ្នា យ៉ាងពិតប្រាកដ**
**ពេលនោះព្រះជាអម្ចាស់ គង់ជាមួយយើង**
**ពេលណាយើងរួបរួមគ្នា ពេលនោះព្រះជាអម្ចាស់ប្រទានពរឲ្យយើង**

២-សូមព្រះបិតាជាម្ចាស់ជាព្រះពន្លឺ ! ប្រោសប្រទានឲ្យគូស្រករថ្មី មានចិត្តស្រឡាញ់គ្នាយ៉ាងស្មោះអស់មួយជីវិត សូមឲ្យគេចេះគោរព យោគយល់ អនុគ្រោះ ឲ្យគ្នាជានិច្ចទាំងពេលសប្បាយរីករាយ និងទាំងពេលមានទុក្ខព្រួយផង ។ (បន្ទរ)

៣-សូមព្រះបិតាជាម្ចាស់ ជាព្រះសង្គ្រោះ ! ក្នុងដំណើរជីវិតអាពាហ៍ពិពាហ៍ យើងខ្ញុំដឹងថា ពិតជាមានការលំបាក ការរស់នៅរបស់មនុស្សនិងមនុស្ស ប្រសិនបើគ្មានព្រះអំណោយទានមកពីព្រះអង្គទេ មនុស្សលោកមិនអាចរស់នៅជាមួយគ្នាបានទេ ។ សូមព្រះអង្គគង់នៅជាមួយគូស្រករថ្មីនេះ និងប្រទានឲ្យពួកគាត់រស់នៅជាមួយគ្នាអស់មួយជីវិត ចេះរស់នៅតាមក្រិត្យវិន័យរបស់ព្រះជាម្ចាស់ដោយចិត្តស្មោះត្រង់ចេះអប់រំណែនាំ កូនរបស់ខ្លួន ឲ្យដើរតាមមាគ៌ារបស់ព្រះអង្គផង ។ (បន្ទរ)

៤- បពិត្រព្រះនាងម៉ារី ជាមាតានៃសន្តិភាព តាមរយៈព្រះនាង និងសន្តយ៉ូសែប ធ្វើឲ្យគម្រោងការដ៏អស្ចារ្យព្រះជាម្ចាស់បានកើតមកជារូបរាង គឺព្រះបុត្រា បានប្រសូតមកជាមនុស្ស ដើម្បីបង្ហាញពីសេចក្តីស្រឡាញ់ របស់ព្រះអង្គសម្រាប់មនុស្សលោកទាំងឡាយ ។ សូមព្រះនាងជួយទូលអង្វរព្រះជាម្ចាស់ សម្រាប់អស់យុវជនទាំងអស់ក្នុងប្រទេសកម្ពុជា បានពោរពេញដោយសេចក្តីស្រឡាញ់ និងប្តេជ្ញាចិត្តសម្រាប់ សេ

ចក្តីស្រឡាញ់ រស់នៅសម្រាប់សេចក្តីស្រឡាញ់ ដោយជៀសវៀងគ្រប់អំពើអបាយមុខផ្សេងៗ និងសូមឲ្យគូស្រករថ្មីនេះ ចេះរស់នៅយ៉ាងសុភាពរាបសារ ចេះពឹងផ្អែក និងជឿសង្ឃឹមលើព្រះជាម្ចាស់ដោយចិត្តស្រឡាញ់ និង ចេះចែករំលែកផលប្រយោជន៍របស់ខ្លួនឲ្យអ្នកដទៃ តាមគំរូរបស់ព្រះនាងផង។ (បន្ទរ)

ប. បពិត្រព្រះបិតាជាអម្ចាស់ សូមទ្រង់ព្រះមេត្តាអាណិតអាសូរដល់ប្អូនទាំងពីរនាក់នេះ ដែលផ្សំផ្គុំគ្នាជាគូស្វាមី-ភរិយា សូមទ្រង់ប្រោសប្រណីឲ្យប្អូនទាំងពីរនេះមានចិត្តស្មោះអស់មួយជីវិត និងធ្វើជាពន្លឺសម្រាប់ណែនាំអ្នកដទៃផង។

យើងខ្ញុំសូមអង្វរព្រះអង្គ ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះបុត្រា ព្រះអង្គ និងជាអម្ចាស់យើងខ្ញុំ ។

គ. *អាម៉ែន។*

- *ប្រសិនបើពិធីអាពាហ៍ពិពាហ៍ មានអភិបូជា សូមបន្ត "ពិធីអរព្រះគុណដ៏វិសុទ្ធ"។*
- *បើសិនអត់មានអភិបូជាទេ សូមរំលងទៅដល់ "ពិធីទទួលព្រះកាយនិងព្រះលោហិត"។*

## ពិធីអរព្រះគុណដ៏វិសុទ្ធ

*លោកបូជាចារ្យ អញ្ជើញឡើងទៅលើតុអាសនៈ ដើម្បីបន្តថ្វាយអភិបូជា*

**ចម្រៀងថ្វាយតង្វាយ**

### សូមលើកតង្វាយថ្វាយព្រះបិតា

១- ឱ ! ព្រះបិតា ជាព្រះជាម្ចាស់ លើសកលលោក យើងខ្ញុំទាំងឡាយ
សូមលើកតង្វាយ រួមទាំងចិត្តកាយ ថ្វាយព្រះបិតា ។
២- យើងខ្ញុំសូមថ្វាយ នំស្រាតង្វាយ ដែលទ្រង់ប្រទាន សូមទ្រង់មេត្តា
ប្រោសឱ្យនំស្រា ក្លាយជាព្រះកាយ ព្រះលោហិតព្រះគ្រីស្ត ។
៣- សូមទ្រង់មេត្តា ទទួលដំណើរ ជីវិតយើងខ្ញុំ សូមប្រោសយើងខ្ញុំ
ឱ្យស្អាតបរិសុទ្ធ ដូចជាតង្វាយ ដែលយើងលើកថ្វាយ ។

ប.	បពិត្រព្រះជាអម្ចាស់នៃពិភពលោកទាំងមូល!

យើងខ្ញុំសូមសរសើរតម្កើងព្រះអង្គ

ដ្បិតយើងខ្ញុំទទួលនំប៉័ងនេះ ពីព្រះហប្ញទ័យសប្បុរសរបស់ព្រះអង្គ។

យើងខ្ញុំសូមលើកនំប៉័ងនេះ ដែលជាផលផ្លែនៃទឹកដី

និងការងាររបស់មនុស្សលោក ថ្វាយទៅព្រះអង្គវិញ។

សូមឲ្យនំប៉័ងនេះ ទៅជាអាហារដែលផ្តល់ជីវិតសម្រាប់យើងខ្ញុំ។

**ឆ្លើយៈ** ***សូមសរសើរតម្កើងព្រះជាអម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ។***

*លោកបូជាចារ្យចាក់ទឹក លាយជាមួយស្រាទំពាំងបាយជូរ ហើយអធិដ្ឋានខ្សឹបៗ*

ដូចទឹកលាយជាមួយស្រានេះ ដោយគម្រោងការដ៏អស្ចារ្យយ៉ាងណា

សូមឲ្យយើងខ្ញុំបានចូលរួមក្នុងសភាពជាព្រះជាម្ចាស់របស់ព្រះគ្រីស្ត

ដែលបានបន្ទាបខ្លួន ចូលរួមក្នុងសភាពជាមនុស្សយ៉ាងនោះដែរ។

ប.	បពិត្រព្រះជាអម្ចាស់នៃពិភពលោកទាំងមូល !

យើងខ្ញុំសូមសរសើរតម្កើងព្រះអង្គ

ដ្បិតយើងខ្ញុំ ទទួលស្រាទំពាំងបាយជូរ ពីព្រះហប្ញទ័យសប្បុរសរបស់ព្រះអង្គ។

យើងខ្ញុំសូមលើកស្រានេះ ដែលជាផលផ្លែនៃដើមទំពាំងបាយជូរ

និងការងាររបស់មនុស្សលោក ថ្វាយទៅព្រះអង្គវិញ។

សូមឲ្យស្រាតង្វាយនេះទៅជាភេសជ្ជៈដែលផ្តល់ការសង្គ្រោះសម្រាប់យើងខ្ញុំ

**គ្រ.**	***សូមសរសើរតម្កើងព្រះជាម្ចាស់ អស់កល្បជាអង្វែងតរៀងទៅ***

*លោកបូជាចារ្យ អធិដ្ឋានខ្សឹបៗ*

ឱ ព្រះអម្ចាស់អើយ !សូមទ្រង់មេត្តាទទួលយើងខ្ញុំ

ដែលមានចិត្តសុភាពរាបសា

និងសោកស្តាយដោយបានប្រព្រឹត្តអំពើបាប។

សូមទ្រង់ប្រោសឲ្យសក្ការបូជា ដែលយើងខ្ញុំថ្វាយនៅថ្ងៃនេះ

បានគាប់ព្រះហប្ញទ័យព្រះជាអម្ចាស់ផង។

*លោកបូជាចារ្យ លាងដៃដោយ អធិដ្ឋានខ្សឹបៗ*

ឱ ព្រះអម្ចាស់អើយ !

សូមលុបលាងកំហុសរបស់ខ្ញុំឲ្យបានស្អាតទាំងស្រុង

សូមជម្រះខ្ញុំឲ្យបានបរិសុទ្ធរួចពីបាប។

**ប.** សូមបងប្អូនតាំងចិត្តអធិដ្ឋាន៖ សូមឲ្យសក្ការបូជារបស់ខ្ញុំ និងរបស់បងប្អូនបានគាប់ព្រះហឫទ័យព្រះជាម្ចាស់ ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ។

គ្រ. *សូមព្រះអម្ចាស់ទទួលសក្ការបូជាពីដៃរបស់លោក ទុកជាការលើកតម្កើងសិរីរុងរឿងព្រះនាមព្រះអង្គ និងជាប្រយោជន៍ដល់យើងខ្ញុំ ព្រមទាំងព្រះសហគមន៍ទាំងមូលរបស់ព្រះអង្គផង។*

## ពាក្យថ្វាយតង្វាយ

បពិត្រព្រះជាម្ចាស់ដ៏វិសុទ្ធ សូមព្រះអង្គទទួលសក្ការបូជាដែលយើងខ្ញុំ មកថ្វាយក្នុងឱកាសអាពាហ៍ពិពាហ៍របស់គូស្រករថ្ងៃនេះ។ សូមឲ្យជីវិតអាពាហ៍ពិពាហ៍ ដែលព្រះអង្គប្រទានដោយព្រះហឫទ័យមេត្តាករុណានេះ នឹងបង្កើតផលតាមព្រះបំណងរបស់ព្រះអង្គផង

យើងខ្ញុំសូមទូលអង្វរព្រះអង្គ ដោយរួមជាមួយព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធ អស់កល្បជាអង្វែង តរៀងទៅ។

គ្រ. *អាម៉ែន។*

# ធម៌អរព្រះគុណដ៏វិសុទ្ធទី ២

ប.  សូមព្រះអម្ចាស់គង់នៅជាមួយបងប្អូន។

**គ្រ.  ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង។**

ប.  សូមលើកចិត្តថ្វាយព្រះអង្គ។

**គ្រ.  យើងលើកចិត្តថ្វាយព្រះអង្គហើយ។**

ប.  សូមអរព្រះគុណ ព្រះជាអម្ចាស់នៃយើងខ្ញុំ។

**គ្រ.  ពិតជាការគួរណាស់ ហើយប្រពៃផង។**

## ធម៌ប្រារព្ធ

បពិត្រព្រះអម្ចាស់ ជាព្រះបិតាដ៏វិសុទ្ធ !
ជាព្រះជាអម្ចាស់ដ៏ខ្ពង់ខ្ពស់ ហើយមានព្រះជន្មអស់កល្បជានិច្ច
ពិតជាការគួរណាស់ហើយប្រពៃផង
ដែលយើងខ្ញុំសូមអរព្រះគុណព្រះអង្គគ្រប់ពេលវេលា និងគ្រប់ទិសទី
ដោយរួមជាមួយព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គ។
ព្រះអង្គសព្វព្រះហឫទ័យឲ្យមនុស្សដែលទ្រង់បង្កើតមក
ដោយព្រះហឫទ័យមេត្តា បានទទួលកិត្តិយសយ៉ាងខ្ពស់
ឲ្យសេចក្តីស្រឡាញ់យ៉ាងពិតប្រាកដរបស់ព្រះអង្គ បានឃើញក្នុងការរួមរស់គ្នា រវាងមនុស្សប្រុសនិងមនុស្សស្រី ដែលព្រះអង្គបង្កើតដោយសេចក្តីស្រឡាញ់នោះ ឲ្យពួកគាត់មកកាន់វិន័យនៃសេចក្តីស្រឡាញ់ ដើម្បីព្រះអង្គអាចប្រោសឲ្យពួកគាត់មានចំណែកក្នុងសេចក្តីស្រឡាញ់និរន្តរ៍របស់ព្រះអង្គ។ អាពាហ៍ពិពាហ៍ដ៏វិសុទ្ធ ដែលជាគម្រោងការដ៏អស្ចារ្យនេះ ដ៏រាបណា អាពាហ៍ពិពាហ៍នេះជាសញ្ញា បង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គ ក៏ធ្វើឲ្យសេចក្តីស្រឡាញ់របស់មនុស្សនោះដ៏វិសុទ្ធ ដោយបារមីរបស់ព្រះអម្ចាស់ព្រះគ្រីស្ត។

អាស្រ័យហេតុនេះហើយ បានជាយើងខ្ញុំសូមចូលរួមជាមួយអស់ទេវទូត
និងអស់សន្តបុគ្គល រួមគ្នាលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ
ដោយសូរស័ព្ទតែមួយថា ៖

**ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ ! ព្រះដ៏វិសុទ្ធ !**
**ព្រះអង្គជាព្រះអម្ចាស់ នៃពិភពទាំងមូល**
**មេឃនិងដី ពោរពេញដោយសិរីរុងរឿងរបស់ព្រះអង្គ។**
**ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត**
**សូមលើកតម្កើងព្រះអង្គ**
**ដែលយាងមកក្នុងព្រះនាមព្រះអម្ចាស់។**
**ជយោ ! ព្រះអង្គឯស្ថានដ៏ខ្ពង់ខ្ពស់បំផុត។**

ឱ ព្រះអម្ចាស់អើយ !
ព្រះអង្គពិតជាព្រះដ៏វិសុទ្ធ និងជាប្រភពនៃភាពដ៏វិសុទ្ធគ្រប់យ៉ាង។
យើងខ្ញុំសូមទូលអង្វរព្រះអង្គ
សូមប្រោះព្រះវិញ្ញាណរបស់ព្រះអង្គដូចទឹកសន្សើម
មកញ៉ាំងតង្វាយទាំងនេះឲ្យបានវិសុទ្ធ គឺសូមឲ្យតង្វាយនេះ
**បានទៅជាព្រះកាយ + និងព្រះលោហិតព្រះអម្ចាស់ព្រះយេស៊ូគ្រីស្ត**
**សម្រាប់យើងខ្ញុំ។**
នៅគ្រាដែលព្រះយេស៊ូគ្រីស្តសព្វព្រះហឫទ័យ
ឲ្យគេបញ្ជូនព្រះអង្គទៅសោយទុក្ខលំបាក
ព្រះអង្គយកនំបុ័ងមកកាន់
អរព្រះគុណព្រះបិតា
ហើយកាច់ប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

**" សូមអ្នករាល់គ្នាយកពិសាចុះ**
**នេះជារូបកាយរបស់ខ្ញុំ**
**ដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា"។**

នៅពេលចុងក្រោយនៃពិធីជប់លៀង ព្រះអង្គធ្វើតាមរបៀបដដែល
ព្រះអង្គលើកពែងឡើង អរព្រះគុណព្រះបិតា
ហើយប្រទានឲ្យក្រុមសាវ័ក ទាំងមានព្រះបន្ទូលថា ៖

**" សូមអ្នករាល់គ្នាយកពែងនេះ ហើយពិសាចុះ**
**នេះជាលោហិតរបស់ខ្ញុំ ដែលចងសម្ព័នមេត្រីថ្មី**
**និងគង់វង្សអស់កល្បជានិច្ច ហើយដែលត្រូវបង្ហូរ**
**ដើម្បីលើកលែងទោសអ្នករាល់គ្នា**
**និងមនុស្សច្រើនឥតគណនាឲ្យរួចពីបាប។**
**សូមអ្នករាល់គ្នាធ្វើដូច្នេះ ដើម្បីនឹករឭកដល់ខ្ញុំ "។**

ប. នេះជាគម្រោងការដ៏អស្ចារ្យនៃជំនឿ !

**គ្រ. ឱ ព្រះអម្ចាស់អើយ! យើងខ្ញុំជឿថា ព្រះអង្គសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ ហើយយើងខ្ញុំសូមប្រកាស រហូតដល់ពេលព្រះអង្គយាងមក។**

បពិត្រព្រះអម្ចាស់! ក្នុងពេលដែលយើងខ្ញុំនឹករឭក
ដល់ព្រះបុត្រាសោយទិវង្គត និងមានព្រះជន្មរស់ឡើងវិញ
យើងខ្ញុំសូមថ្វាយព្រះកាយដែលផ្តល់ជីវិត និងព្រះលោហិតដែលផ្តល់ការសង្គ្រោះ
ព្រមទាំងអរព្រះគុណព្រះអង្គ
ដ្បិតទ្រង់សព្វព្រះហឫទ័យឲ្យយើងខ្ញុំ
សមនឹងស្ថិតនៅ ចំពោះព្រះភ័ក្ត្រ និងបម្រើព្រះអង្គ។

យើងខ្ញុំសូមលំទោនកាយទូលអង្វរ
សូមព្រះអង្គប្រោសប្រទានព្រះវិញ្ញាណដ៏វិសុទ្ធប្រមូលផ្តុំយើងខ្ញុំ
ដែលចូលរួមក្នុងព្រះកាយ និងព្រះលោហិតរបស់ព្រះគ្រីស្ត
ឲ្យទៅជាធ្លុងតែមួយផង។

បពិត្រព្រះអម្ចាស់! សូមព្រះអង្គនឹកដល់ព្រះសហគមន៍
ដែលមាននៅសព្វអន្លើក្នុងពិភពលោកទាំងមូល
សូមប្រោសឲ្យព្រះសហគមន៍ បានគ្រប់លក្ខណៈក្នុងសេចក្តីស្រឡាញ់
រួមជាមួយសម្តេចប៉ាបយើងខ្ញុំ...
លោក នាម... ជាអភិបាលព្រះសហគមន៍យើងខ្ញុំ
និងអស់លោកអ្នកដែលមានបន្ទុកដឹកនាំប្រជារាស្ត្រព្រះអង្គ។

សូមព្រះអង្គនឹកដល់អស់បងប្អូនយើងខ្ញុំ
ដែលសម្រាន្តលក់ដោយមានចិត្តសង្ឃឹមនឹងរស់ឡើងវិញ
ព្រមទាំងបុគ្គលទាំងអស់ដែលបានលាចាកលោកនេះ
ក្នុងធម៌មេត្តាករុណារបស់ព្រះអង្គ។
សូមព្រះអង្គប្រោសប្រទានឲ្យបុគ្គលទាំងនោះ
បានចូលក្នុងពន្លឺនៃព្រះភ័ក្ត្រព្រះអង្គ។

សូមព្រះអង្គអាណិតអាសូរយើងខ្ញុំទាំងអស់គ្នា
បានទទួលជីវិតអស់កល្បជានិច្ច រួមជាមួយព្រះនាងព្រហ្មចារិនីម៉ារី
ដែលពោរពេញដោយសុភមង្គល ជាព្រះមាតារបស់ព្រះជាម្ចាស់
រួមជាមួយសន្តយ៉ូសែបជាស្វាមីព្រះនាង
ជាមួយអស់គ្រីស្តទូត និងអស់សន្តបុគ្គលនៅគ្រប់សម័យ
ដែលគាប់ព្រះហឫទ័យព្រះអង្គ។

យើងខ្ញុំទាំងអស់គ្នាសូមកោតសរសើរ
និងលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ។
ដោយរួមជាមួយព្រះយេស៊ូគ្រីស្តជាព្រះបុត្រាព្រះអង្គ។

**ឱ ព្រះជាម្ចាស់ជាព្រះបិតាដ៏មានឫទ្ធានុភាពសព្វប្រការ !**
**គឺដោយព្រះគ្រីស្ត ជាមួយព្រះគ្រីស្ត និងក្នុងអង្គព្រះគ្រីស្ត**
**រួមជាមួយព្រះវិញ្ញាណដ៏វិសុទ្ធផង**
**បានជាយើងខ្ញុំ សូមលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ**
**អស់កល្បជាអង្វែងតរៀងទៅ។**
***ឆ្លើយៈ  អាម៉ែន។***

## ពិធីទទួលព្រះកាយ និងព្រះលោហិត

*ប្រសិនបើអត់មានអភិបូជាទេ។ ពីធម៌សាកល សូមរំលងមកចាប់ផ្តើមបន្តពីទីនេះ។*

**ប.** តាមដំបូន្មានរបស់ព្រះយេស៊ូជាព្រះសង្គ្រោះនិងតាមការប្រៀនប្រដៅរបស់ព្រះអង្គយើងខ្ញុំហ៊ានទូលថា

*ឱ ព្រះបិតាយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ !*
*សូមសម្តែងព្រះបារមី ឲ្យមនុស្សលោកស្គាល់ព្រះនាមព្រះអង្គ*
*សូមឲ្យព្រះរាជ្យព្រះអង្គបានមកដល់*
*សូមឲ្យព្រះហឫទ័យរបស់ព្រះអង្គ*
*បានសម្រេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ។*

*សូមប្រទានអាហារ ដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ។*
*សូមអត់ទោសឲ្យយើងខ្ញុំ ដូចយើងខ្ញុំអត់ទោសឲ្យអស់អ្នក*
*ដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ។*
*សូមកុំបណ្តោយឲ្យយើងខ្ញុំ ចាញ់ការល្បួងឡើយ។*
*តែសូមរំដោះយើងខ្ញុំ ឲ្យរួចពីមារកំណាច។*

# ព្រះពរពិសេសសម្រាប់គូស្រករ

*លោកបូជាចារ្យបន្តនិយាយៈ*

បងប្អូនជាទីស្រឡាញ់ សូមឲ្យយើងរួមចិត្តគំនិតអធិដ្ឋានអង្វរព្រះជាម្ចាស់ប្រោសប្រទានពរឲ្យគូស្រករថ្ងៃនេះ ឲ្យទំនាក់ទំនងនៃអាពាហ៍ពិពាហ៍របស់គាត់ទាំងពីររីកចម្រើនឡើង។

បពិត្រព្រះបិតាដែលបង្កើតពិភពលោក ព្រះអង្គបង្កើតមនុស្សប្រុសនិងមនុស្សស្រីតាមលក្ខណៈដូចព្រះអង្គ ហើយទ្រង់សព្វព្រះហឫទ័យឲ្យការរួមរស់របស់ពួកគាត់ទទួលព្រះពរពីព្រះអង្គ។ យើងខ្ញុំទាំងអស់គ្នាសូមទូលអង្វរព្រះអង្គដើម្បីឲ្យកូនក្រមុំ(ឈ្មោះ)..................ដែលថ្ងៃនេះជាឆ្លងតែមួយជាមួយនឹងកូនកំលោះ(ឈ្មោះ).......................តាមរយៈទំនាក់ទំនងនៃអាពាហ៍ពិពាហ៍។

បពិត្រព្រះជាម្ចាស់ សូមប្រោសប្រទានព្រះពររបស់ព្រះអង្គយ៉ាងបរិបូរណ៍មកលើកូនក្រមុំ និងគូជីវិតរបស់នាង ដើម្បីឲ្យការរួមរស់ជាមួយគ្នាទៅវិញទៅមកនោះ បង្កើតផលនៃអំណររីករាយ គឺ បង្កើតកូន ហើយធ្វើឲ្យព្រះសហគមន៍ និងប្រទេសជាតិរីកចម្រើនតរៀងទៅ។

បពិត្រព្រះជាម្ចាស់ សូមឲ្យគាត់ទាំងពីរ កោតសរសើរអរព្រះគុណព្រះអង្គនៅពេលមានក្ដីសុខ ហើយទុកចិត្តហៅរកព្រះអង្គ នៅពេលមានក្ដីទុក្ខ។ សូមឲ្យគាត់មានអំណរសប្បាយ ដោយដឹងថា ព្រះអង្គសណ្ឋិតនៅជាមួយគាត់ជានិច្ចដើម្បីជួយគាំទ្រ ទាំងនៅពេលមានការលំបាក និងលួងលោមពេលគាត់មានទុក្ខព្រួយ។ សូមឲ្យគាត់ទាំងពីរជួយគ្នាទៅវិញទៅមក ដោយរស់នៅជាសាក្សីនៃ សេចក្ដីល្អនិងព្រះហឫទ័យមេត្តារបស់ព្រះអង្គរហូតក្នុងជីវិតរបស់ពួកគាត់ ក្នុងចំណោមមនុស្ស ពេលដល់វ័យចាស់ជរាដោយសុខសាន្ត ក្នុងចំណោមមិត្តភ័ក្ត្រហើយ សូមឲ្យគាត់ទាំងពីរបានដល់ស្ថានបរមសុខផង ដោយព្រះបារមីរបស់ ព្រះគ្រីស្តនៃយើងខ្ញុំ។

***គ្រ. អាម៉ែន។***

- *ប្រសិនបើអត់មានអភិបូជាទេ សូមរំលងទៅពិធី បញ្ចប់។*

*(ក្នុងករណី គូស្រករភាគីកាតូលិកប្រាថ្នាទទួលព្រះកាយ សូមលោកបូជាចារ្យក្រាលកម្រាលពិសិដ្ឋលើតុសក្ការៈ ហើយទៅអញ្ជើញព្រះកាយមកដាក់នៅលើអាសនៈ។ សូមរំលងទៅបង្ហាញ " នេះជាកូនចៀមរបស់ព្រះជាម្ចាស់ ..." ហើយអញ្ជើញព្រះកាយជូនឲ្យគូស្រករដែលជាកាតូលិក។ ក្រោយមកបន្តទៅពិធីបញ្ចប់។)*

ប. ឱ ព្រះអម្ចាស់យេស៊ូគ្រីស្តអើយ !
ព្រះអង្គមានព្រះបន្ទូលទៅកាន់ក្រុមគ្រីស្តទូតថា ៖
«ខ្ញុំទុកសេចក្តីសុខសាន្តឲ្យអ្នករាល់គ្នា
ខ្ញុំផ្តល់សេចក្តីសុខសាន្តរបស់ខ្ញុំឲ្យអ្នករាល់គ្នា»។
សូមព្រះអង្គកុំប្រកាន់ទោសរបស់យើងខ្ញុំឡើយ
តែសូមទ្រង់ឈ្វេងយល់ នូវជំនឿរបស់ព្រះសហគមន៍ព្រះអង្គវិញ។
សូមព្រះអង្គសព្វព្រះហឫទ័យប្រទានឲ្យព្រះសហគមន៍
បានប្រកបដោយសេចក្តីសុខសាន្ត និងបានមូលផ្តុំគ្នាជាធ្លុងតែមួយ។
ព្រះអង្គមានព្រះជន្មគង់នៅនិងសោយរាជ្យអស់កល្បជាអង្វែងតរៀងទៅ។

*គ. អាម៉ែន។*

ប. សូមឲ្យសេចក្តីសុខសាន្តរបស់ព្រះអម្ចាស់ គង់នៅជាមួយបងប្អូន។

***គ. ហើយគង់នៅជាមួយវិញ្ញាណរបស់លោកផង។***

ប. សូមបងប្អូនជូនសេចក្តីសុខសាន្ត ចំពោះគ្នាទៅវិញទៅមក។

**ឱ! កូនចៀមរបស់ព្រះជាម្ចាស់ !ដែលដកបាបនៃពិភពលោក
សូមអាណិតអាសូរយើងខ្ញុំ។**

**ឱ! កូនចៀមរបស់ព្រះជាម្ចាស់ !ដែលដកបាបនៃពិភពលោក
សូមអាណិតអាសូរយើងខ្ញុំ។**

**ឱ! កូនចៀមរបស់ព្រះជាម្ចាស់ !ដែលដកបាបនៃពិភពលោក**
**សូមប្រទានសេចក្តីសុខសាន្តឲ្យយើងខ្ញុំ។**

*លោកបូជាចារ្យ កាត់នំប៉័ង ហើយដាក់ចំណែកតូចក្នុងពែងស្រា ដោយអធិដ្ឋានខ្សឹបៗ*
*ឱ ព្រះអម្ចាស់យេស៊ូគ្រីស្ត ! ជាព្រះបុត្រានៃព្រះជាម្ចាស់ដែលមានព្រះជន្មគង់នៅ*
*ព្រះអង្គប្រទានជីវិតឲ្យពិភពលោកទាំងមូល ដោយសោយទិវង្គតតាមព្រះហឫទ័យព្រះបិតា*
*និងដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធ ។*
*សូមរំដោះខ្ញុំឲ្យរួចផុតពីបាប និងសេចក្តីអាក្រក់ទាំងឡាយ*
*ដោយសារព្រះកាយ និងព្រះលោហិតដ៏វិសុទ្ធបំផុតរបស់ព្រះអង្គ។*
*សូមឲ្យខ្ញុំប្រព្រឹត្តតាមឱវាទរបស់ព្រះអង្គជានិច្ច កុំឲ្យខ្ញុំឃ្លាតឆ្ងាយពីព្រះអង្គឡើយ។*

ប. នេះជាកូនចៀមរបស់ព្រះជាម្ចាស់
នេះជាព្រះអង្គដែលដកបាបនៃពិភពលោក ។
អ្នកណាដែលព្រះជាម្ចាស់បានត្រាស់ហៅ
ឲ្យមកចូលរួមក្នុងពិធីជប់លៀងរបស់កូនចៀម
អ្នកនោះពិតជាមានសុភមង្គលហើយ ។

គ. **ឱ ព្រះអម្ចាស់អើយ ! ខ្ញុំមិនសមនឹងទទួលព្រះអង្គក្នុងផ្ទះខ្ញុំទេ**
**តែសូមព្រះអង្គមានព្រះបន្ទូលតែមួយព្រះឱស្ឋមក**
**នោះព្រលឹងខ្ញុំនឹងជាសះស្បើយ។**

## ពាក្យអរព្រះគុណ

ប. ឱ ព្រះអម្ចាស់ជាព្រះសង្គ្រោះ!
ព្រះអង្គបានប្រទានព្រះកាយ និងព្រះលោហិតព្រះគ្រីស្តឲ្យយើងខ្ញុំ។
សូមសេចក្តីពិតរបស់ព្រះអង្គបំភ្លឺចិត្តគំនិតយើងខ្ញុំ
ឲ្យចេះស្រឡាញ់ព្រះអង្គអស់មួយជីវិត។
យើងខ្ញុំសូមអង្វរព្រះអង្គដោយរួមជាមួយព្រះយេស៊ូជាព្រះគ្រីស្ត
និងជាអម្ចាស់យើងខ្ញុំ។ អាម៉ែន។

## ចម្រៀងទទួលព្រះកាយ

### ចូរអ្នកស្វះស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់

បន្ទរៈ ចូរអ្នកស្វះស្វែងរកព្រះរាជ្យរបស់ព្រះជាម្ចាស់
និងសេចក្ដីសុចរិតរបស់ព្រះអង្គជាមុនសិន
ទើបព្រះអង្គប្រទានរបស់ទាំងនោះមកថែមទៀត
ដ្បិតព្រះបិតាអ្នក ជ្រាបនូវអ្វីដែលអ្នកត្រូវការ ។

១- ព្រះគ្រីស្តមានព្រះបន្ទូលថា ចូរអ្នកមើលបក្សាបក្សី
វាមិនដែលសាបព្រោះច្រូតកាត់ តែព្រះបិតាចិញ្ចឹមវា
ចំណែកឯអ្នករាល់គ្នាវិញ អ្នករាល់គ្នាមានតម្លៃពិត
លើសបក្សាបក្សីទៅទៀត ហេតុនេះចូរអ្នកកុំខ្វល់ខ្វាយ ។
២- ព្រះគ្រីស្តមានព្រះបន្ទូលថា ចូរអ្នកមើលផ្កាតាមវាលស្រែ
វាមិនដែលនឿយហត់ត្បាញរវៃ តែទោះជាស្ដេចសាឡូមូន
កាលទ្រង់មានសិរីរុងរឿង ក៏ទ្រង់គ្មានព្រះភូសាល្អ
ស្មើនឹងផ្កាមួយទងនេះផង ហេតុនេះចូរអ្នកកុំខ្វល់ខ្វាយ ។

ឬ-

### ពរពីព្រះជាម្ចាស់

១,(ស) ព្រះជាម្ចាស់ស្រឡាញ់យើង ព្រោះយើងជាបុត្រធីតាព្រះជាម្ចាស់
ទ្រង់ស្រឡាញ់នឹងថែរក្សាយើង ឲ្យយើងមានសេចក្ដីសុខសាន្ត។
២,(ប) សូមព្រះជាម្ចាស់ទ្រង់ប្រទានពរ ឲ្យដល់គូស្វាមីភរិយាស្រឡាញ់គ្នា
ស្មោះត្រង់អស់មួយជីវិត ចេះរិះគិតបង្ហាញក្ដីស្រឡាញ់។

បន្ទ:(រួម) ដោយមានព្រះអម្ចាស់គង់ជាមួយ ព្រះអង្គជួយបង្ហាញសេចក្ដីស្រឡាញ់
សូមព្រះជាអម្ចាស់ទ្រង់ប្រទានពរ ឲ្យសំបូរសប្បាយ មាសសុភមង្គល។
(ច្រៀង២ដង)

៣,(ប) សូមព្រះម្ចាស់ទ្រង់ប្រទានពរ (ស) ឲ្យដល់គូស្វាមីភរិយា
(ប) ស្រឡាញ់គ្នាស្មោះត្រង់អស់មួយជីវិត
(រួម) ចេះរិះគិតបង្ហាញក្ដីស្រឡាញ់។

ឬ **គ្រួសារដ៏វិសុទ្ធ**

១, យើងខ្ញុំសូមលើកតម្កើងអរព្រះគុណព្រះជាអម្ចាស់
ដែលព្រះអង្គករុណាប្រទានសន្តយ៉ូសែបមក ។
លោកជាឪពុកដ៏ល្អសម្រាប់ព្រះកុមារយេស៊ូ
ជាគំរូរួមជាមួយព្រះនាងម៉ារីក្នុងជំនឿ ។
២, ក្ដីស្រឡាញ់ដ៏កក់ក្ដៅ និងភាពរឹងមាំគួរជាពំនឹង
ចិត្តស្មោះស្ម័គ្រភក្ដីភាព និងទឹកចិត្តដូចមហាសាគរ
យើងខ្ញុំសូមគោរពកោតសរសើរសន្តយ៉ូសែប
រួមទៅដល់ព្រះនាងម៉ារី យើងរាល់គ្នាសូមអធិដ្ឋាន ។

**បន្ទរ ឱ សន្តយ៉ូសែបព្រះនាងម៉ារី ដ៏ឧត្តមអើយ ! សូមជួយយើងខ្ញុំរាល់គ្នា
ឲ្យមានចិត្តស្រឡាញ់ និងការអត់ឱនដូចដែលលោកបានស្រឡាញ់ព្រះនាងម៉ារី
អាចធ្វើរឿងដែលត្រឹមត្រូវល្អ ដូចអ្នកទាំងពីរធ្វើជាគំរូដល់ព្រះយេស៊ូ
និងមានជំនឿជឿជាក់យ៉ាងស្មោះស្ម័គ្រដូចអ្នកទាំងពីរផ្ញើជីវិត
ទាំងស្រុកលើព្រះជាម្ចាស់។**

៣, ព្រះនាងដ៏សែនទន់ភ្លន់ជាគំរូនៃភាពរាបសារ
ស្នាមញញឹមសែនស្រស់ថ្លាជាភាពសុខសាន្តនៃលោកយ៉ូសែប
ព្រះនាងពិតជាគំរូនៃជំនឿយ៉ាងពិតប្រាកដ
ខ្ញុំសូមលើកតម្កើងកោតសរសើរព្រះនាងដ៏ថ្លាថ្លៃ ។

៤, ព្រះនាងម៉ារីដ៏វិសុទ្ធសថ្លាដូចសំឡី
ដោយជំនឿនាងដោគជ័យយកឈ្នះការលំបាកទាំងឡាយ
ប្រសូតបុត្រាដ៏តូចដែលនឹងនាំពួកយើងរាល់គ្នា
ឲ្យទៅដល់ព្រះបិតាជាទីស្រឡាញ់យ៉ាងពិតប្រាកដ។

## ពិធីបញ្ចប់

*✢ លោកបូជាចារ្យធ្វើព្រះពរលើគូស្វាមី-ភរិយាថ្មី*

បពិត្រព្រះបិតាដ៏មានតេជានុភាពសព្វប្រការ សូមព្រះអង្គប្រោសប្រទានឲ្យប្អូនទាំងពីរប្រកបដោយ អំណរសប្បាយគ្រប់ពេលវេលាអស់មួយជីវិត ។

**បន្ទរៈ មានសុភមង្គលហើយ មានសុភមង្គលហើយ មានសុភមង្គលហើយ!**

*(បាចផ្កាស្លា ៣ ដង)*

សូមព្រះយេស៊ូគ្រីស្ត ជាព្រះបុត្រារបស់ព្រះបិតា ថែរក្សាការពារប្អូនទាំងពីរ និងសូមទ្រង់ព្រះមេត្តាលើកទឹកចិត្តប្អូនក្នុងពេលកើតទុក្ខព្រួយផង ។

**បន្ទរៈ មានសុភមង្គលហើយ មានសុភមង្គលហើយ មានសុភមង្គលហើយ!**

*(បាចផ្កាស្លា ៣ ដង)*

សូមព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះជាម្ចាស់ប្រោសប្រទានធម៌មេត្តាករុណាឲ្យប្អូនទាំងពីរ។

**បន្ទរៈ មានសុភមង្គលហើយ មានសុភមង្គលហើយ មានសុភមង្គលហើយ!**

*(បាចផ្កាស្លា ៣ ដង)*

សូមព្រះជាម្ចាស់ដ៏មានឫទ្ធានុភាពសព្វប្រការ ប្រទានព្រះពរដល់អស់បងប្អូន គឺព្រះបិតា និងព្រះបុត្រា ✠ និងព្រះវិញ្ញាណដ៏វិសុទ្ធ។

*លោកបូជាចារ្យអញ្ជើញ គូស្វាមី-ភរិយាថ្មី និងបន្ទាល់សាក្សីចុះហត្ថលេខា លើសៀវភៅចុះឈ្មោះអាពាហ៍ពិពាហ៍។ ក្រោយចុះហត្ថលេខាហើយ គូស្វាមីភរិយាថ្មី ទៅអធិដ្ឋានអរគុណនិងសូម ព្រះពរពីព្រះនាងម៉ារី ផ្ញើជីវិតគ្រួសារលើព្រះនាង។*

| | | | | |
|---|---|---|---|---|
| **បន្ទរ:** | **ចូរអបអរ** | **ចូលសរសើរ** | **ចូលច្រៀងថ្វាយមាតាព្រះ** | |
| | **ចូរអបអរ** | **ចូលសរសើរ** | **ចូលច្រៀងថ្វាយម៉ារីយ៉ា ។** | |

| | | | |
|---|---|---|---|
| ១- | សូមក្រាបសំពះព្រះនាង | ជាមាតាថ្លៃនៃព្រះ | |
| | តារាសមុទ្រលោកា | ជាទ្វារនៃស្ថានបរមសុខ | ។ |
| ២- | សូមផ្តាច់ចំណងអ្នកបាប | បំភ្លឺដល់អ្នកងងឹត | |
| | អាសូរកម្ចាត់គ្រោះថ្នាក់ | ផ្តល់នូវសុភមង្គល | ។ |
| ៣- | សិរីរុងរឿងមានដល់ | ព្រះបិតាព្រះបុត្រា | |
| | និងព្រះវិញ្ញាណដ៏វិសុទ្ធ | អស់កល្បជារាបទៅមុខ | ។ |

## ពាក្យថ្លែងអំណរគុណរបស់គូស្រករ

## ចម្រៀងចេញ

### ព្រះពរដល់គូស្វាមីភរិយាថ្មី

បន្ទរៈ ថ្ងៃនេះជាថ្ងៃដែលព្រះជាម្ចាស់ ប្រទានពរជ័យឲ្យមាន
ដល់គូស្វាមីភរិយាថ្មី រួមរស់នឹងគ្នា ។
អនាគតជីវិតមានគូ រួមសុខរួមទុក្ខក្នុងក្ដីស្រឡាញ់
និងជ្រកក្រោមម្លប់បារមីព្រះជាម្ចាស់ ។

១. ស្នេហ៍ស្មោះស្ម័គ្រ ដោយចិត្តថ្លើមតែមួយ ស្រឡាញ់អស់សង្ខារ មិនកែប្រែ
បងពិតជាស្មោះ អូនពិតជាស្ម័គ្រ ថ្វាយព្រះបិតា ដូចក្ដីស្រឡាញ់ នៃព្រះជាម្ចាស់
ផ្ដល់អំណោយទាន ដល់គូរៀបការ ចម្រើនផល្លា ពរជ័យសិរី មង្គលថ្លៃថ្លា ។

២. ទោះថ្ងៃក្រោយ មានទុក្ខលំបាកអ្វី ចិត្តភក្ដី មិនភ្លេចពាក្យសច្ចា រួមចិត្តគំនិត
ចែករំលែកទុក្ខ ស្មោះត្រង់នឹងគ្នា មានចិត្តធម៌មេត្តាករុណា រិតចំណងមេត្រី
ក្នុងព្រះគុណ សុភមង្គល អស់មួយជីវិត ក្នុងព្រះបិតា

